# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី១

LECTURE 1

## សេចក្តីផ្តើមនៃនីតិអន្តរជាតិសាធារណៈ

INTRODUCTION TO PUBLIC INTERNATIONAL LAW

## មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្តីផ្តើម
- ផ្នែកទី២ នីតិអន្តរជាតិ និងសង្គមអន្តរជាតិ
    - នីតិអន្តរជាតិ និងនីតិមនុស្សជាតិ
    - នីតិអន្តរជាតិ និងនីតិអន្តររដ្ឋ
    - នីតិអន្តរជាតិ និងសហាគមន៍អន្តរជាតិ
- ផ្នែកទី៣ ការវិវឌ្ឍនៃនីតិអន្តរជាតិ
    - ដំណើរវិវឌ្ឍនៃនីតិអន្តរជាតិ
    - ស្ថាប័នភាវូបនីយកម្មនីតិអន្តរជាតិ
    - លក្ខណៈជាសាកលនៃនីតិអន្តរជាតិ
- ផ្នែកទី៤ ផ្នែកទី៥ នីតិអន្តរជាតិសហាសម័យ
    - ឋានានុក្រមនៃនីតិអន្តរជាតិ
    - តួអង្គនៃនីតិអន្តរជាតិ

# កម្មវត្ថុនៃមេរៀន

មេរៀនស្តីអំពី សេចក្តីផ្តើមនៃនីតិអន្តរជាតិសាធារណៈ មានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពី៖

- អ្វីទៅជានីតិអន្តរជាតិសាធារណៈ
- អ្វីទៅជានីតិអន្តរជាតិឯកជន
- ការវិវត្តន៍នៃនីតិអន្តរជាតិសាធារណៈ
- យល់ពីភាពគ្មានឋានានុក្រមនៃនីតិអន្តរជាតិ
- យល់ពីតួអង្គដែលចូលរួមបង្កើតនីតិអន្តរជាតិសធារណៈ

# ផ្នែកទី១ សេចក្ដីផ្ដើម

នីតិអន្តរជាតិសាធារណៈ គឺជាវិធានដែលបង្កើតឡើងក្នុងគោលបំណងថែរក្សាទំនាក់ទំនងនៃតួអង្គរបស់វា។ ដែលតួអង្គនៃនីតិអន្តរជាតិរួមមាន៖ រដ្ឋ និងអង្គការអន្តរជាតិ។

លោក ដាវីន រុយហ្សេ បានផ្ដល់នូវនិយមន័យនៃនីតិអន្តរជាតិសាធារណៈថា គឺជាបណ្ដាលវិធានច្បាប់ដែលអនុវត្តចំពោះតួអង្គនសង្គមអន្តរជាតិ។

# ផ្នែកទី១ សេចក្ដីផ្ដើម

នីតិអន្តរជាតិសាធារណៈ ក៏ត្រូវបានអះអាងថាជាវិធានកំណត់ពីទំនាក់ទំនងរវាងតួអង្គនៃនីតិអន្តរជាតិនៅក្នុងសង្គមអន្តរជាតិ ហើយក៏ជាវិធាននៃការការហាមប្រាម និងក៏ជាវិធានដែលអនុញ្ញាតនៅក្នុងការបំពេញនូវកិច្ចការណាមួយដែលតួអង្គនោះជាប់កាតព្វកិច្ច។

# ផ្នែកទី១ សេចក្តីផ្តើម

នីតិអន្តរជាតិត្រូវបានគេធ្វើការបែងចែងជាពីរធំៗគឺ៖

1. នីតិអន្តរជាតិសាធារណៈ
2. នីតិអន្តរជាតិឯកជន

# ផ្នែកទី១ សេចក្តីផ្តើម

១. នីតិអន្តរជាតិធារណៈ គឺបញ្ញត្តិអំពីការធ្វើទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ និងរវាងរដ្ឋ និងអង្គការអន្តរជាតិ។

២. នីតិអន្តរជាតិឯកជន គឺបញ្ញត្តិអំពីការធ្វើទំនាក់ទំនងរវាងតួអង្គដែលមិនមែនជារដ្ឋ ឬអង្គការអន្តរជាតិដែលមានដូចជារូបវន្ត ឬនីតិបុគ្គលឯកជនដែលមានចំណងបុគ្គលភាពគតិយុត្តផ្សេងៗគ្នា។

# ផ្នែកទី១ សេចក្ដីផ្ដើម

ដូច្នេះ នីតិអន្តរជាតិសាធារណៈត្រូវបានបង្កើតឡើងក្នុងគោលបំណង ថែរក្សានូវសណ្ដាប់ធ្នាប់ក្នុងការធ្វើទំនាក់ទំនងតែរវាងតួអង្គរបស់វាតែប៉ុណ្ណោះ មិនសំដៅទៅដល់ការគ្រប់គ្រងតួអង្គផ្សេងទៀតនោះឡើយ។

# ផ្នែកទី២ នីតិអន្តរជាតិ និងសង្គមអន្តរជាតិ

ប្រសិនបើយើងនិយាយពីនីតិ គឺយើងសំដៅទៅដល់វិធាន ប៉ុន្តែប្រសិនបើយើងនិយាយពីសសង្គមវិញ គឺយើងសំដៅទៅដល់តួអង្គ។ ដូច្នេះ សង្គមអន្តរជាតិ គឺមានន័យថាជាសហាគមន៍នៃរដ្ឋ ឬអង្គការអន្តរជាតិ (អង្គការអន្តររដ្ឋ) នៅលើផែនដី។

# ផ្នែកទី២ នីតិអន្តរជាតិ និងសង្គមអន្តរជាតិ

ពាក្យថាសហាគមន៍អន្តរជាតិ គឺវាបានកើតឡើងពីភាពចម្រុះគ្នានៃតួអង្គនៃនីតិអន្តរជាតិ ដូច្នេះហើយទើបគេបានធ្វើការអះអាងថា សហាគមន៍អន្តរជាតិ គឺជាសហាគមន៍ ចម្រុះវិមជ្ឈការ ទំនាស់ និងជាសហាគមន៍ដែលមានសាមគ្គីភាព។

# ផ្នែកទី២ នីតិអន្តរជាតិ និងសង្គមអន្តរជាតិ

ជាសហាគមន៍ចម្រុះ ក៏ដោយសារតែរដ្ឋទាំងឡាយនៅលើផែនដីគឺមានលក្ខណៈចម្រុះគ្នា គឺមានរដ្ឋធំ រដ្ឋតូច រដ្ឋអ្នកមាន រដ្ឋក្រ មាននិន្នាការនយោបាយ សេដ្ឋកិច្ច សាសនា សង្គម វប្បធម៌ ខុសៗគ្នា ជាអាទិ៍។

# ផ្នែកទី២ នីតិអន្តរជាតិ និងសង្គមអន្តរជាតិ

ជាសហាគមន៍វិមជ្ឈការ ក៏ដោយសារតែរដ្ឋទាំងឡាយត្រូវមានអធិបតេយ្យ ដូច្នេះគ្មានរដ្ឋណាមួយធំជាងរដ្ឋណាឡើយ (អំណាច)។ ក្នុងក្របខណ្ឌច្បាប់អន្តរជាតិ ហើយក៏ដូចមានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាតិ រដ្ឋទាំងឡាយត្រូវតែស្មើគ្នាចំពោះមុខច្បាប់។

# ផ្នែកទី២ នីតិអន្តរជាតិ និងសង្គមអន្តរជាតិ

ជាសហាគមន៍ទំនាស់ ក៏ដោយសារតែរដ្ឋទាំងឡាយលើផែនដីមានលក្ខណៈចម្រុះនោះហើយ គឺរដ្ឋនោះតែងតែចង់នូវអំណាច គៀងគរនូវបក្សពួក មនោគមន៍វិជ្ជាបែបជាធិបតេយ្យ ឬមនោគមន៍វិជ្ជាបែបគុម្មុនីស ជាអាទ៍។

# ផ្នែកទី២ នីតិអន្តរជាតិ និងសង្គមអន្តរជាតិ

ជាសហគមន៍ដែលមានសាមគ្គីភាព នោះក៏ដោយសារតែតួអង្គទាំងឡាយនៃនីតិអន្តរជាតិ បានរួមគ្នាក្នុងការកសាងសហគមន៍ដែលមានសន្តិភាព និងរួបរួមគ្នាបង្កើតបាននូវប្រព័ន្ធនៃការគ្រប់គ្រងរួម ឧទាហរណ៍ជាក់ស្តែងរដ្ឋបានរួមគ្នាក្នុងការបង្កើតឲ្យអង្គការសហប្រជាជាតិ ជាអាទិ៍។

# នីតិអន្តរជាតិ និងមនុស្សជាតិ

នីតិមនុស្សជាតិ JUS GENTIUM វាគឺជាពាក្យត្រូវបានគេប្រើសម្រាប់សំដៅទៅដល់នីតិដែលគ្រប់គ្រងការធ្វើទំនាក់ទំនងរវាងរដ្ឋនៅក្នុងសង្គមអន្តរជាតិទាំងមូល ហើយដែលធាតុពិតទៅនីតិនេះ មិនមានអ្វីខុសគ្នាពីនីតិអន្តរជាតិនោះឡើយ គ្រាន់តែវាត្រូវបានគេនិយមប្រើនៅក្នុងពេលវេលាខុសតែប៉ុណ្ណោះ (នីតិអន្តរជាតិ គេនិយមប្រើក្នុងពេលបច្ចុប្បន្ន)។

# នីតិអន្តរជាតិ និងអន្តររដ្ឋ

ដូចបានបកស្រាយពីខាងដើម នីតិអន្តរជាតិត្រូវបានគេនិយមប្រើក្នុងពេលបច្ចុប្បន្ន។ ការហៅ ឬប្រើពាក្យអន្តររដ្ឋមើលទៅដូចជាមានលក្ខណៈចង្អៀតជាង ដែលសំដៅតែទៅការធ្វើទំនាក់ទំនងរវាងរដ្ឋមួយ និងរដ្ឋមួយតែតែប៉ុណ្ណោះ តែការពិតពាក្យទាំងពីរនេះគឺមានន័យតែមួយ ដូចទៅនិងពាក្យនីតិមនុស្សជាតិដូច្នេះដែរ (ប្រើមួយណាក៏បាន)។

# នីតិអន្តរជាតិ និងសហគមន៍អន្តរជាតិ

- នីតិអន្តរជាតិ គឺគេសំដៅទៅដល់វិធានដែលត្រូវបានបង្កើតឡើងក្នុងការគ្រប់គ្រងទំនាក់ទំនងរវាងតួអង្គរបស់វា។
- សហគមន៍អន្តរជាតិ គឺសំដៅទៅដល់តួអង្គដែលចូលរួមក្នុងការបង្កើតនូវបណ្តាលវិធាន សម្រាប់យកមកធ្វើការគ្រប់គ្រងទំនាក់ទំនងតួអង្គនៃនីតិអន្តរជាតិ។

# ផ្នែកទី៣ ការវិវឌ្ឍន៍នៃនីតិអន្តរជាតិ

ទោះជានីតិអន្តរជាតិ បានកើតឡើងជាយូរលង់ណាស់មកហើយក៏ដោយ វាក៏នៅតែត្រូវបានគេចាត់ទុកថាជានីតិមួយថ្មីដែរ។ ការលើកឡើងបែបនេះ ក៏ព្រោះតែនីតិនេះវាទើបត្រូវបានគេផ្តល់តម្លៃឲ្យវានៅសតវត្សទី២០ និងសតវត្សទី២១នេះតែប៉ុណ្ណោះ គឺតាមរយៈរូបភាពនៃការធ្វើស្ថាប័នភាវូបនីយ និងសាកលភាវូបនីយកម្មនៃនីតិអន្តរជាតិ។

# ដំណើរវិវឌ្ឍន៍នៃនីតិអន្តរជាតិ

នីតិអន្តរជាតិ គឺជាប្រព័ន្ធនិយ័តកម្មគតិយុត្តក្នុងការធ្វើទំនាក់ទំនងនៃរដ្ឋអធិបតេយ្យ។ ប្រសិនបើគេពិនិត្យទៅលើការកកើតនៃនីតិអន្តរជាតិ នីតិអន្តរជាតិសាធារណៈ គឺជានីតិមួយដែលមានវ័យចំណាស់ជាងគេ បើយើងប្រៀបធៀបជាមួយនិងប្រវត្តិនៃការកកើតឡើងនៃពិភពលោក។

# ដំណើរវិវឌ្ឍន៍នៃនីតិអន្តរជាតិ

ការកើតឡើងនូវអាណាចក្រធំពីសម័យបុរាណ ហើយដែលបានពើបប្រទះនូវការផ្លាស់ប្តូរ ទៅវិញទៅមករវាងសន្តិភាព និងសង្គ្រាម។ ការផ្លាស់ប្តូរនេះ បានធ្វើឲ្យតួអង្គទាំងឡាយនាំគ្នាគោរពនូវវិធានគតិយុត្ត ដូចជាសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានា។ តែទោះជាយ៉ាងណាក៏ដោយគេក៏មើលឃើញថា នៅមានការបំពារបំពានគ្នារវាងគូប្រឆាំង និងសម្ព័ន្ធមិត្ត។

# ដំណើរវិវឌ្ឍន៍នៃនីតិអន្តរជាតិ

ចាប់ពីសតវត្សទី១៦មក គេសង្កេតឃើញថាទម្រង់នៃរដ្ឋទំនើបបានកកើតឡើង ជាពិសេសគឺនៅទ្វីបអឺរ៉ុប។ ហើយការកើតឡើងនូវរដ្ឋទំនើបនេះ គឺជាប្រភពនៃការបង្កើតច្បាប់ដែលមានឆន្ទៈគោរពនូវច្បាប់ដែលពួកគេបានបង្កើតនោះ។ និយាយដោយខ្លី រដ្ឋជាអ្នកបង្កើតច្បាប់ ហើយក៏ជាអ្នកគោរពច្បាប់ដែលខ្លួនបានបង្កើតនោះផងដែរ។

# ដំណើរវិវឌ្ឍន៍នៃនីតិអន្តរជាតិ

ច្បាប់នៅពេលកើតដំបូង ត្រូវបានយកតាមគំរូនៃច្បាប់នៃបណ្តាលរដ្ឋអឺរ៉ុប ហើយត្រូវបានសាយភាយទៅដល់រដ្ឋដ៏ទៃទៀតនៃបណ្តាលទ្វីបផ្សេងទៀតមានដូចជា ទ្វីបអាមេរិក ទ្វីបអាហ្វ្រិក និងទ្វីបអាស៊ីជាដើម។ ពេលនោះហើយដែលនីតិអន្តរជាតិត្រូវបានធ្វើការកែទម្រង់ឲ្យទៅជានីតិមួយដែលមានលក្ខណៈពិសេសសម្រាប់សង្គមអន្តរជាតិ។

# ស្ថាប័នភាវូបនីយកម្មនៃនីតិអន្តរជាតិ

ការបង្កើតនូវវិធានដែលមានលក្ខណៈជាសកល បានបញ្ជាក់ពីការរីកចម្រើនបន្តិចម្តងៗក្នុងវិស័យបច្ចេកវិទ្យា និងឈានទៅដល់ការរីកចម្រើនខាងផ្នែកនយោបាយ និងទំនាក់ទំនងអន្តរជាតិ។ នីតិអន្តរជាតិដែលជាឧបករណ៍បុរាណ ត្រូវបានប្រែក្លាយទៅជាឧបករណ៍ទំនើបចាប់ពីចុងសតវត្សទី១៩មក។

# ដំណើរវិវឌ្ឍន៍នៃនីតិអន្តរជាតិ

ការកែប្រែពីឧបករណ៍បុរាណឲ្យទៅជាឧបករណ៍ទំនើបនៃនីតិអន្តរជាតិនេះបានស្តែងឡើងតាមរូបភាពនៃការបង្កើតឲ្យមានសន្ធិសញ្ញាសន្តិភាពនានានៅសតវត្សទី១៧-១៨។ ដែលកាលពីមុនសន្ធិសញ្ញាទាំងនេះ ត្រូវបានបង្កើតឡើងក្នុងទម្រង់ពីសន្ធិសញ្ញាទ្វេភាគី ទៅជាទម្រង់ពហុភាគី និងទម្រង់ជាពហុភាគីទូទៅ។

# ដំណើរវិវឌ្ឍនៃនីតិអន្តរជាតិ

នៅសតវត្សទី១៩ អង្គការអន្តររដ្ឋាភិបាល (អង្គការអន្តរជាតិ) ជាច្រើនត្រូវបានបង្កើតឡើង ហើយនៅពេលនោះវាមានទម្រង់ជាអង្គការបច្ចេកទេសច្រើនជាង។ ឧទាហរណ៍ដូចជាសហភាពទូរគមនាគមន៍អន្តរជាតិ និងគណៈកម្មការអឺរ៉ុបសម្រាប់ទន្លេដានុប ជាដើម។

# ដំណើរវិវឌ្ឍន៍នៃនីតិអន្តរជាតិ

ការកើតឡើងនូវមជ្ឈត្តការអន្តរជាតិ សម្រាប់ធ្វើការដោះស្រាយវិវាទអន្តរជាតិក៏ត្រូវបានបង្កើតឡើងជាហូហែរផងដែរ។ ឧទាហរណ៍ ការបង្កើតឲ្យមានមជ្ឈត្តការសម្រាប់ការដោះស្រាយវិវាទរវាងប្រទេសអង់គ្លេស និងសហរដ្ឋអាមេរិកឆ្នាំ១៨៧២ ជាអាទ៍។

# លក្ខណៈជាសាកលនៃនីតិអន្តរជាតិ

ការបង្កើតឲ្យមាននូវអង្គការអន្តរជាតិច្រើន បានបង្ហាញយ៉ាងច្បាស់ពីលក្ខណៈជាសាកលនៃនីតិអន្តរជាតិ ដែលក្នុងរួមការបង្កើតនូវសង្គមប្រជាជាតិ និងអង្គការសហប្រជាជាតិជាឧទាហរណ៍ដែលមិនអាចប្រកែកបាន។ តាមការបង្កើតនូវស្ថាប័នអន្តរជាតិទាំងនេះ បានបង្ហាញនូវការដាក់តម្កល់នូវផលប្រយោជន៍រួមរបស់មនុស្សជាតិជាធំ។

# ផ្នែកទី៤ នីតិអន្តរជាតិសហសម័យ

ការវិវត្តនៃនីតិអន្តរជាតិ បានបញ្ជាក់យ៉ាងច្បាស់ពីការផ្លាស់ប្តូរនូវប្រព័ន្ធគតិយុត្តអន្តរជាតិ ដែលអាចត្រូវបានយកមកប្រើក្នុងយុគសម័យ និងសម័យទំនើប។ ការធ្វើសំយោគរវាងវិធានបុរាណ និងវិធានបែបទំនើប បានធ្វើឲ្យមនុស្សជាតិ អាចបង្កើតបាននូវប្រព័ន្ធគតិយុត្តដែលមានលក្ខណៈល្អប្រសើរ សម្បូរបែប និងអាចបត់បែនបាន។

# ឋានានុក្រមនៃនីតិអន្តរជាតិ

សូមចង់ចាំថា ទោះបីជាមានការប្រែប្រួលពីសម័យកាលមួយទៅសម័យកាលមួយយ៉ាងណាក៏ដោយ ក៏នៅក្នុងនីតិអន្តរជាតិពុំមានឋានានុក្រមរវាងគ្នានោះទេ។ ការគ្មានឋានានុក្រមនេះ បញ្ជាក់ឲ្យឃើញថា រដ្ឋទាំងឡាយបានតម្កល់នូវគោលការណ៍សមភាពរបស់រដ្ឋជាចម្បង។

# ឋានានុក្រមនៃនីតិអន្តរជាតិ

ការដែលគ្មានឋានានុក្រមនៃវិធាន ឬបទដ្ឋាននេះហើយ បានធ្វើឲ្យរដ្ឋទាំងឡាយពុំមានការបែងចែកនូវឋានៈ ថារដ្ឋណាមួយតូច ឬធំក្នុងក្រុមខណ្ឌនៃនីតិអន្តរជាតិ។ រដ្ឋទាំងអស់ត្រូវមានភាពស្មើគ្នាចំពោះមុខច្បាប់ និងគោរពគ្នាទៅវិញទៅមក ក្នុងនាមជារដ្ឋអធិបតេយ្យ។

# តួអង្គនៃនីតិអន្តរជាតិ

ទោះបីជាមានការទាមទារពីរដ្ឋមួយចំនួនក៏ដោយ ដើម្បីឲ្យមានការទទួលស្គាល់តួអង្គផ្សេងទៀត ថាជាតួអង្គនៃនីតិអន្តរជាតិ ក៏រហូតមកដល់បច្ចុប្បន្ននេះ គឺមានតែតួអង្គចំនួនពីរទេដែលត្រូវបានទទួលស្គាល់។ តួអង្គទាំងពីរនេះរួមមាន៖

1. រដ្ឋ
2. អង្គការអន្តរជាតិ (អង្គការអន្តររដ្ឋាភិបាល)

មេរៀនទី១ ត្រូវបានបញ្ចប់ សូមអរគុណសម្រាប់ការតាមដាន ដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។